**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jul-2015, 15:30
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ(កោសលុប)

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានា ស្ដីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងឈុតវីដេអូដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត Rob Lemkin និង ថេត សម្បត្តិ**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រ៊ីម, ប្រធាន
ចៅក្រម A. KLONOWIECKA- MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASIINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele NUMBA

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Anta GUISSÉ
លោក Arthur VERCKEN

# I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាសូមឆ្លើយតបទៅនឹង "ចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានាស្ដីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងឈុតវីដេអូ ដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត Rob Lemkin និង ថេត សម្បត្តិ" ("ចម្លើយតប")[1]។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ បន្ទាប់ពីសំណើទីមួយរបស់ នួន ជា សុំឱ្យទទួលយក និងពិចារណាលើភស្ដុតាងបន្ថែមនៅក្នុងកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខនៃសំណុំរឿង០០២/០១[2] អង្គជំនុំជម្រះតុលាការកំពូល ("អជតក" ឬ "អង្គជំនុំជម្រះ") បានសម្រេចផ្ដួចផ្ដើមកិច្ចស៊ើបសួរបន្ថែម ដើម្បីកំណត់ថាតើឈុតវីដេអូដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់ Robert Lemkin និង ថេត សម្បត្តិ អាចត្រូវបានទទួលយកក្នុងអំឡុងពេលសមស្របដែរឬទេ ហើយថាបើសមស្រប អង្គជំនុំជម្រះនឹងទទួលយកឈុតវីដេអូនេះ[3]។ ជាផ្នែកមួយនៃកិច្ចស៊ើបសួរបន្ថែមនេះដែរ អជតក បានសម្ភាសន៍ជាមួយ Lemkin[4] ដែលពេលក្រោយមកគាត់បានផ្ដល់ជូន អជតក នូវកំណត់ហេតុនេះ ដែលគាត់បានរៀបចំឡើង ("កំណត់ហេតុ")[5]។ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ អជតក បានសុំឱ្យ នួន ជា ដាក់សារណាជាលាយល័ក្ខណ៍អក្សរ (១) ថាតើកំណត់ហេតុនេះគួរដាក់ចូលជាភស្ដុតាងដែរឬទេ និង (២) ថាតើគួរមានវិធានការណាមួយបន្ថែមទៀតដោយចៅក្រមទទួលសិទ្ធិ ឬអង្គជំនុំជម្រះ ទាក់ទងព័ត៌មានដែលចេញមកពីកិច្ចស៊ើបសួរបន្ថែមដែរឬទេ[6]។ នៅក្នុងចម្លើយតបរបស់គាត់ នួន ជា សុំឱ្យទទួលយកកំណត់ហេតុបញ្ចូលជាភស្ដុតាង និងស្នើឱ្យ អជតក សម្ភាសន៍ Lemkin ឡើងវិញ សម្ភាសន៍ ថេត

---

[1] **F2/4/3/3/1** ចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានាស្ដីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងឈុតវីដេអូ ដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត Rob Lemkin និង ថេត សម្បត្តិ, ១៣ កក្កដា ២០១៥ ("ចម្លើយតប")។

[2] **F2** សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្ដុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង០០២/០១, ១ កញ្ញា ២០១៤, កថាខណ្ឌ១៧។

[3] **F2/4/3** សេចក្ដីសម្រេចបណ្ដោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជាសុំឱ្យទទួល និងពិចារណាទៅលើភស្ដុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង០០២/០១, ១ មេសា ២០១៥, កថាខណ្ឌ២៦។

[4] **F2/4/3/1** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី Robert T. F. Lemkin, ១៨ ឧសភា ២០១៥ ("កំណត់ហេតុនៃការស្ដាប់ចម្លើយ Lemkin")។

[5] **F2/4/3/3.1** ឧបសម្ព័ន្ធ - កំណត់ហេតុស្ដីពីកិច្ចស៊ើបសួរជម្លោះផ្ទៃក្នុងខ្មែរក្រហមដែលមិនបានបោះពុម្ពផ្សាយ, ២៩ ឧសភា ២០១៥ ("កំណត់ហេតុ")។

[6] **F2/4/3/3** សេចក្ដីសម្រេចស្នើឱ្យដាក់សារណាស្ដីពីកិច្ចស៊ើបសួរបន្ថែម, ១៥ មិថុនា ២០១៥។

សម្បត្តិ និងកោះហៅពួកគេទាំងពីរមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ[7]។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះគួរតែច្រានចោលសំណើសុំទាំងនេះ អាស្រ័យដូចមូលហេតុជម្រាបជូនខាងក្រោម។

## II. ច្បាប់ជាធរមាន

2. ក្រោមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង មានលក្ខខណ្ឌតម្រូវចំនួនបីដែលត្រូវបំពេញ នៅពេលភាគីណាមួយស្នើឱ្យទទួលយកភស្តុតាងថ្មី នៅក្នុងដំណាក់នៃដំណើរការបណ្តឹងសាទុក្ខ។ ភាគីអ្នកស្នើសុំត្រូវកំណត់ថា ភស្តុតាងថ្មីដែលខ្លួនស្នើឱ្យទទួលយកនោះ (១) មិនអាចរកបាននៅពេលសវនាការ; (២) អាចជាកត្តាកំណត់ដើម្បីឈានដល់ការសម្រេចនៅក្រោមបណ្តឹងសាទុក្ខ និង (៣) ពាក់ព័ន្ធទៅនឹងការរកឃើញជាក់លាក់ណាមួយនៃអង្គហេតុដោយអង្គជំនុំជម្រះ[8]។

3. សម្រាប់លក្ខខណ្ឌទីមួយ អជតក បានសង្កត់ធ្ងន់ថា ការបង្ហាញថា ភស្តុតាងមិនអាចរកបាននៅពេលសវនាការ បើទោះបីជាបានខំប្រឹងប្រែងព្យាយាមយ៉ាងហ្មត់ចត់ក៏ដោយ "គឺជាចំណុចសំខាន់ខានមិនបាន ដើម្បីបញ្ចៀសយុទ្ធសាស្ត្រវិវាទកម្មកុំឱ្យមានការរាំងស្ទះ និងគ្មានប្រសិទ្ធភាព"[9]។ សំខាន់បំផុតសម្រាប់បញ្ហានៅចំពោះមុខ លក្ខខណ្ឌតម្រូវទីពីរ បង្កើតបទដ្ឋានកម្រិតខ្ពស់មួយសម្រាប់ការទទួលយកភស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខ។ ក្រៅអំពីគ្រាន់តែមានការពាក់ព័ន្ធ ភស្តុតាងត្រូវតែមានទម្ងន់ និងសារៈសំខាន់ដែលអាចប្រើជា "កត្តាកំណត់ដើម្បីឈានដល់ការសម្រេចសេចក្តីនៅសវនាការ"។ បទដ្ឋានកម្រិតខ្ពស់ដូច្នេះ គឺជាចំណុចសំខាន់ខានមិនបាន ដើម្បីបញ្ចៀសកុំឱ្យបណ្តឹងសាទុក្ខកាន់តែថមថយនៅក្នុងសវនាការទីពីរ ដើម្បីកុំឱ្យពន្យារពេលដល់កិច្ចដំណើរការនីតិវិធីហួសហេតុ និង/ឬ លើកកម្ពស់ការចូលរួមវិវាទកម្មដោយគ្មានប្រសិទ្ធភាព[10]។

---

[7] **F2/4/3/3/1** ចម្លើយតប, កថាខណ្ឌ៨-៩។

[8] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី១៦ ខែមករា ឆ្នាំ ២០១៥ (វិធានផ្ទៃក្នុង"), វិធាន ១០៨(៧)។

[9] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ២៩ ឧសភា ២០១៥, សេចក្តីសម្រេចរបស់តុលាការកំពូល ត្រង់កថាខណ្ឌ ១៦។

[10] *រដ្ឋអាជ្ញា ទល់នឹង Kupreškić និងគូកន.*, IT-95-16-A, សេចក្តីសម្រេចលើញត្តិរបស់ Drago Josipović, Zoran Kupreškić និង Vlatko Kupreškić សុំឱ្យទទួលយកភស្តុតាងបន្ថែម អនុលោមតាមវិធាន១១៥ និងសុំឱ្យចាត់វិធានការសច្ចទស្សន៍តុលាការ អនុលោមវិធាន៩៤(ខ), ៨ ឧសភា ២០០១, ត្រង់កថាខណ្ឌ ៣។

ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌទីបីនេះ សំខាន់គេត្រូវកត់សម្គាល់ថា បើអនុលោមតាមពាក្យពេចន៍ធម្មតារបស់វិធាននេះ ពាក្យថាភ័ស្តុតាងថ្មីត្រូវតែពាក់ព័ន្ធទៅនឹងការរកឃើញជាក់លាក់ណាមួយនៃអង្គហេតុរបស់អង្គជំនុំជម្រះ មិនមែនតាមអំណះអំណាងរបស់ភាគីណាមួយឡើយ។

4. វិធាន១០៤(១) ផ្តល់ឲ្យ អជតក នូវអំណាចឆន្ទានុសិទ្ធិ ដើម្បីទទួលយកភ័ស្តុតាងថ្មី "ប្រសិនបើផលប្រយោជន៍នៃយុត្តិធម៌តម្រូវ ដោយផ្អែកលើកាលៈទេសៈជាក់លាក់នៃករណី"[11]។ ដើម្បីកំណត់ដូច្នេះ អង្គជំនុំជម្រះនឹងត្រូវពិចារណាថាតើ ភ័ស្តុតាងនោះនឹងនាំទៅដល់ការស្វែងរកការពិត ដែរឬយ៉ាងណា[12]។

5. វិធាន២១(១) ចែងនូវផ្នែកពាក់ព័ន្ធថា "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។

## III. ចម្លើយតប

### ក. ការទទួលយកភ័ស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខគួរត្រូវបានធ្វើតែក្នុងកាលៈទេសៈវិសាមញ្ញប៉ុណ្ណោះ

6. ដំណាក់កាលជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ បានធ្វើឡើងអស់រយៈពេល២១៤ថ្ងៃ នៃថ្ងៃសវនាការ[13]។ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មបុគ្គល៩២នាក់ រួមទាំងអ្នកជំនាញបីនាក់ផង[14]។ ប្រតិចារឹករួមបញ្ចូលគ្នានៃកិច្ចដំណើរការនីតិវិធីសរុបប្រហែល២៥,០០០ទំព័រ និងឯកសារជាភ័ស្តុតាងចំនួន៥,៨០០ឯកសារ ដែលសរុបប្រហែល ២២២,០០០ទំព័រ គ្រប់ភាសាទាំងបី ដែលបានទទួលយក បន្ទាប់ពីបានផ្តល់ឱកាសឲ្យមានការជជែកដេញដោលជាសាធារណៈរួចមក[15]។

---

[11] **F2/5** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្តឹងសាទុក្ខ, ត្រង់កថាខណ្ឌ ១៧។

[12] *ដដែលដូចខាងលើ*។

[13] **E313** សាលក្រមនៃសំណុំរឿង០០២/០១, ៧ សីហា ២០១៤ ("សាលក្រមសាលាដំបូង"), កថាខណ្ឌ៨។

[14] *ដដែលដូចខាងលើ*, កថាខណ្ឌ៣២។

[15] *ដដែលដូចខាងលើ*, កថាខណ្ឌ៣៣។

7. បន្ទាប់ពីសវនាការវែង ការសម្រេចណាមួយដើម្បីទទួលយកភ័ស្តុតាងថ្មីដែលបានស្នើឡើងដោយភាគីមួយនៃបណ្តឹងសាទុក្ខ ត្រូវតែអនុវត្តតាមបទដ្ឋានកម្រិតខ្ពស់នៃការទទួលយកភ័ស្តុតាង ដូចបានកំណត់នៅក្នុងវិធាន១០៨(៧)។ បើភ័ស្តុតាងនោះត្រូវបានទទួលយក បន្ទាប់មក អជតក ត្រូវពិចារណាលើភ័ស្តុតាងថ្មីនោះ ទៅតាមបរិបទនៃកំណត់ហេតុនៃភ័ស្តុតាងទាំងមូល ដើម្បីបញ្ចៀសកុំឲ្យមានភាពលំអៀងធម្មតាណាមួយកើតឡើង ដែលផ្តល់ទម្ងន់ខ្លាំងហួសហេតុទៅលើសក្ខីកម្មដែលខ្លួនបានស្តាប់ ឬបានទទួលយកលើសពីភ័ស្តុតាងសម្រាប់បញ្ហាតែមួយដូចគ្នាដែលបានស្តាប់ ឬទទួលយកដោយអង្គជំនុំជម្រះសាលាដំបូង។ លើសពីនេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ប្រសិនបើមានភ័ស្តុតាងថ្មីណាមួយត្រូវបានទទួលយក នោះយុត្តិធម៌ជាមូលដ្ឋាន និងដំណើរការតទល់គ្នានៅ អ.វ.ត.ក ប្រាប់យើងថា ភាគីដទៃក៏ត្រូវទទួលបានឱកាសដោយយុត្តិធម៌ ដើម្បីជំទាស់នឹងភ័ស្តុតាងថ្មីនោះដែរ[16]។ ជាផលប្រយោជន៍ក្នុងការស្វែងការពិត និងវិសមិតភាពទៅនឹងការទទួលបានសវនាការដោយយុត្តិធម៌ ប្រសិនបើព្រមទទួលយកភ័ស្តុតាងថ្មីមួយចំណែកដែលបានស្នើឡើងដោយភាគីមួយ ប៉ុន្តែបដិសេធពុំព្រមទទួលភ័ស្តុតាងថ្មីពីភាគីតទល់ម្ខាងទៀត នៅពេលដែលភ័ស្តុតាងនោះមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការរកឃើញផ្នែកអង្គហេតុដូចគ្នា និងដែលផ្ទុយទៅនឹងភ័ស្តុតាងថ្មីដែលបានទទួលយករបស់ភាគីម្ខាងទៀត។

8. វិធាន១០៨(៧) ជួយបញ្ចៀសស្ថានភាពដែលនាំឲ្យវិវាទកម្មមិនអាចបញ្ចប់បាន និងជួយឲ្យបណ្តឹងសាទុក្ខបានទៅដល់ការជំនុំជម្រះជាថ្មីយ៉ាងមានប្រសិទ្ធិភាព។ ជាការសំខាន់មិនអាចខ្វះបានដែល អជតក អនុវត្តលក្ខខណ្ឌតម្រូវទៅតាមអត្ថន័យដែលគេយល់ដឹងជាធម្មតារបស់វិធាននេះ សម្រាប់គ្រប់សំណើសុំឲ្យទទួលយកភ័ស្តុតាងថ្មីសម្រាប់បណ្តឹងសាទុក្ខទាំងអស់ ទោះជាការទទួលយកដែលបានស្នើឡើងទាំងនោះ ស្របតាមអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ នៅក្រោមវិធាន ១០៤(១) ក៏ដោយ។ បើមិនដូច្នោះទេ អំណាចឆន្ទានុសិទ្ធិនេះ នឹងជួបហានិយភ័យនៃការងាកចេញពីគោលបំណងក្នុងការថែរក្សាបទដ្ឋានកម្រិតខ្ពស់ ដែលកំណត់ពីលក្ខខណ្ឌសម្រាប់ការទទួលយកភ័ស្តុតាងថ្មី ហើយដែលអាចលេបត្របាក់វិធាននេះ។ ភាគីនឹងរារាំងទប់ទល់ជាមួយអង្គជំនុំជម្រះដោយមិនចេះចប់មិនចេះហើយ តាមរយៈការបង្ហាញនូវគោលជំហរចំពោះកំណត់ហេតុ ឬឯកសារណាមួយដែលគេគាំទ្រ ទោះបីជាការពិតភ័ស្តុតាងនោះអាចមិនមែនជាកត្តាកំណត់នៅក្នុងសាលក្រម ឬអាចឲ្យគេរកបាន ប៉ុន្តែមិនបានស្នើឡើងនៅសវនាការដោយភាគីស្នើសុំក៏ដោយ។ ចំណុចនេះ គឺមានការ

[16] តុលាការ ICTY, ICTR និង SCSL សុទ្ធតែបានចែងនៅក្នុងវិធាន ១១៥ របស់គេរៀងៗខ្លួនថា ភាគីដែលប៉ះពាល់ដោយការទទួកលយកភ័ស្តុតាងថ្មីនៅក្នុងអំឡុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ អាចបង្ហាញភ័ស្តុតាងជំទាស់បាន។

ព្រួយបារម្ភ ជាពិសេសក្នុងរឿងក្ដីនៃអំពើឃោរឃៅយ៉ុងឃ្នងធំធេង ដែលមានការពាក់ព័ន្ធនឹងជនរងគ្រោះរាប់ម៉ឺននាក់ និងសាក្សីសក្ខានុពលជាច្រើន ដែលជានិច្ចជាកាលមានសាក្សីជាច្រើនមិនអាចស្វែងរកឃើញ ឬមិនបានស្ដាប់សក្ខីកម្មក្នុងអំឡុងពេលសវនាការ។

## ខ. កំណត់ហេតុមិនអាចជឿទុកចិត្តបាន ហើយតម្លៃភស្ដុតាងមានតិចតួចប៉ុណ្ណោះ

9. កំណត់ហេតុដែលមិនបានបោះពុម្ពផ្សាយរបស់ Lemkin ផ្ដល់សេចក្ដីសង្ខេបនៃបទសម្ភាសន៍របស់ជនអនាមិកដែលបានដឹកនាំធ្វើឡើងនៅក្រោមវិធីសាស្ត្រមិនច្បាស់លាស់។ ពួកគេបានលាយបញ្ចូលនូវភ័ស្តុតាងផ្អែកមតិ និងអំណះអំណាងខាងអង្គហេតុដែលគ្មានប្រភព ដោយបុគ្គលម្នាក់ដែលមិនមែនជាអ្នកជំនាញខាងខ្មែរក្រហម ហើយដែលទំនាក់ទំនងបុគ្គល និង/ឬ មុខជំនួញរបស់គាត់ជាមួយជនជាប់ចោទពោរពេញដោយចំណោទជាច្រើន។ អាស្រ័យដោយមូលហេតុទាំងនេះ និងមូលហេតុដូចបានលើកមកពិភាក្សាខាងក្រោម កំណត់ហេតុនេះមានតម្លៃភស្តុតាងតែបន្តិចបន្តួច មិនអាចជាកត្តាកំណត់សម្រាប់សាលក្រមបានទេ និងមិនគួរទទួលយកបានឡើយ[17]។

10. ទីមួយ កំណត់ហេតុហាក់ដូចជាពឹងផ្អែកជាចំបងទៅលើព័ត៌មានដែលបានផ្ដល់ដោយសាក្សីអនាមិកបួននាក់ ដែលការជម្រុញទឹកចិត្តរបស់ពួកគេក្នុងការហ៊ាននិយាយជាមួយអ្នកថតខ្សែភាពយន្ត គ្មាននរណាដឹងឡើយ។ ដូចបានចង្អុលបង្ហាញយ៉ាងត្រឹមត្រូវដោយ នួន ជា ភ័ស្តុតាងដែលបានទទួលយកក្នុងសំណុំរឿង០០២/០១ រួមមានទាំងភ័ស្តុតាងដែលបានមកពីប្រភពបន្ទាប់បន្សំ ដែលពាក់ផ្អែកលើភ័ស្តុតាងជាមូលដ្ឋានដែលអង្គជំនុំជម្រះមិនអាចរកបាន[18]។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានថ្លែងយ៉ាងច្បាស់ថា ភ័ស្តុតាងបែបនេះនឹងទទួលបានទម្ងន់តិចតួចប៉ុណ្ណោះ[19]។ លើសពីនេះ ភ័ស្តុតាងបានពីប្រភពអនាមិក ជាទូទៅត្រូវបានទទួលយកតែនៅពេលណាបន្ថែមទម្ងន់ទៅឲ្យភ័ស្តុតាងផ្សេងទៀត

---

[17] E313 សាលក្រមសាលាដំបូង, កថាខណ្ឌ៣៥។ សូមមើលផងដែរ វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ E96/7 សេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ២០ មិថុនា ២០១២, កថាខណ្ឌ២៥។

[18] F2/4/3/3/1 ចម្លើយតប, កថាខណ្ឌ៨។

[19] E313 សាលក្រមសាលាដំបូង, កថាខណ្ឌ៣៥។

ឬនៅពេលណាវាមានការពាក់ព័ន្ធនឹងបញ្ហាដែលគ្មានការតវ៉ា[20]ប៉ុណ្ណោះ។ គ្មានកាលៈទេសៈណាមួយក្នុងចំណោមកាលៈទេសៈទាំងនេះ មានអត្ថិភាពនៅក្នុងករណីនេះទេ។

11. ទីពីរ ការព្យាយាមរបស់ នួន ជា ដើម្បីឱ្យតម្លៃនៃកំណត់ហេតុរបស់ Lemkin ស្មើនឹងស្នាដៃរបស់ Philip Short, François Ponchaud និង Stephen Heder[21] គឺជៀសមិនផុតពីបរាជ័យទេ បើយើងធ្វើការប្រៀបធៀបស្នាដៃ និងបទពិសោធន៍របស់បុគ្គលទាំងបីរូបនេះ ជាមួយ Lemkin។ (លើសពីនេះ មិនដូច Lemkin ទេ លោក Short, Ponchaud និង Heder បានផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូង នូវអត្តសញ្ញាណប្រភពសំខាន់ៗរបស់ពួកគេ នៅលើបញ្ហាដែលពួកគេបានផ្តល់សក្ខីកម្ម)។

12. អង្គជំនុំជម្រះសាលាដំបូងបានហៅ Philip Short ថាជាអ្នកជំនាញ និងបានកំណត់ថា "តាមគុណតម្លៃនៃការស្រាវជ្រាវរបស់គាត់ និងការបោះពុម្ពផ្សាយសៀវភៅរបស់គាត់ នៅក្នុងចិរវេលាដែលពាក់ព័ន្ធ" គឺគាត់មាន"ចំណេះដឹងឯកទេសក្នុងផ្នែកជំនាញដូចដែលបានស្នើឡើង"[22]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា គេអាចសួរ Short អំពីអង្គហេតុនានាដែលស្ថិតក្នុងចំណេះដឹងផ្ទាល់ខ្លួនរបស់គាត់ ដែលគាត់ទទួលបានតាមរយៈការធ្វើសម្ភាសន៍ជាមួយមេដឹកនាំ ឬកម្មាភិបាលពីសម័យកាលកម្ពុជាប្រជាធិបតេយ្យ[23]។ លោក Short បានផ្តល់សក្ខីកម្មថា គាត់បានចំណាយពេល៥-៦ឆ្នាំ ដើម្បីសរសេរសៀវភៅ៖ ប៉ុល ពត: ប្រវត្តិនៃសុបិនអាក្រក់ (Pol Pot: The History of a Nightmare)[24]។ ដើម្បីត្រៀមរៀបចំការសរសេរសៀវភៅនេះ គាត់បានដឹកនាំការធ្វើសម្ភាសន៍យ៉ាងទូលំទូលាយជាមួយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") រួមមាន ខៀវ សំផន, អៀង សារី, សុន សេន និងមេដឹកនាំជាន់ខ្ពស់ជាច្រើននាក់ផ្សេងទៀត[25]។ នួន ជា យល់ស្របថា យោង

---

[20] **E313** *ដដែលដូចខាងលើ* ។

[21] **F2/4/3/3/1** ចម្លើយតប, កថាខណ្ឌ៨។

[22] **E215** សេចក្តីសម្រេចចាត់តាំងអ្នកជំនាញ, ៥ កក្កដា ២០១២, កថាខណ្ឌ១៨។

[23] *ដដែលដូចខងលើ* ។

[24] **E1/189.1** ប្រតិចារឹក, ៦ ឧសភា ២០១៣, Philip Short, ទំព័រ៦-៧ [09.15.42-09.20.30]។

[25] **E9/13.1** សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដោយមានចំណុចនៃដីកាដំណោះស្រាយ - ក.ស.ព, ២៣ កុម្ភៈ ២០១១ ("ឧបសម្ព័ន្ធ"), ទំព័រ២០-២១។

តាមជំនាញរបស់គាត់ Short អាចបានផ្តល់សក្ខីកម្មជាទូទៅអំពី បកក និងស្ថានភាពនៃកិច្ចការផ្សេងៗក្នុងកម្ពុជាប្រជាធិបតេយ្យ[26]។

13. François Ponchaud គឺជាអ្នកនិពន្ធអត្ថបទជាច្រើន និងសៀវភៅចំនួនបី រួមមានទាំង កម្ពុជាឆ្នាំសូន្យ (Cambodia Year Zero) ដែលផ្តល់នូវរឿងរ៉ាវយ៉ាងពិស្តារពីជីវិតក្នុងកម្ពុជាប្រជាធិបតេយ្យ[27]។ នៅពេលគាត់បានមកផ្តល់សក្ខីកម្មក្នុងខែមេសា ឆ្នាំ២០១៣ គឺគាត់បានរស់នៅក្នុងប្រទេសកម្ពុជាជាង៤៧ឆ្នាំហើយ[28]។ គាត់បានប្រមូល និងវិភាគលើភ័ស្តុតាងគ្រប់ជ្រុងជ្រោយទាក់ទងនឹងការសម្លាប់ដែលមានការរៀបចំនៃសមាជិកយោធានៃសាធារណរដ្ឋខ្មែរភ្លាមៗ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងរចនាសម្ព័ន្ធ ព្រមទាំង មនោគមវិជ្ជានៃរបបកម្ពុជាប្រជាធិបតេយ្យ[29]។ គាត់បានសម្ភាសន៍ជាមួយជនភៀសខ្លួនរាប់រយនាក់ អំពីបទពិសោធន៍របស់ពួកគេនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបេតយ្យ ក្នុងពេលដែលព្រឹត្តិការណ៍ដែលបានកើតឡើងនៅថ្មីៗនៅឡើយ ហើយគាត់បានកត់សម្គាល់ថា រឿងរ៉ាវជាច្រើនបានបន្ថែមទម្ងន់ទៅលើរឿងរ៉ាវផ្សេងទៀត និងថាបើដូច្នេះ អាចឲ្យពិចារណាបានថា ជារឿងរ៉ាវអាចឲ្យជឿទុកចិត្តបាន[30]។ លោក Ponchaud ក៏មានជំនាញជាច្រើនគួរសមដែរខាងភាសាខ្មែរ ហើយគាត់បានសិក្សាអំពីការផ្សាយ និងពាក្យពេចន៍របស់ខ្មែរក្រហម[31]។

---

[26] **E9/10** សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើង, ២៣ កុម្ភៈ ២០១១។ **E9/10.1** ឧបសម្ព័ន្ធ ឃ៖ សេចក្តីសង្ខេបសាក្សីជាមួយនឹងចំណុចនៃការចោទប្រកាន់ - ក្រុមមេធាវីការពារក្តីលោក នួន ជា, ២៣ កុម្ភៈ ២០១១, ទំព័រ៤៨។ **E93/4** បច្ចុប្បន្នភាពនៃសេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើង, ២១ មិថុនា ២០១១។ **E93/4.3** បញ្ជីបឋម/សេចក្តីសង្ខេបអំពីសាក្សី – ក្រុមមេធាវីការពារក្តី នួន ជា, ២១ មិថុនា ២០១១, ទំព័រ ១២០។

[27] *សូមមើល ឧទាហរណ៍* **E3/370** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី François Ponchaud, ១៣ កុម្ភៈ ២០០៩, ទំព័រ២-៧, ERN (អង់គ្លេស) 00333951-55 (ពន្យល់អំពីការបោះពុម្ពផ្សាយ និងអត្ថបទជាច្រើនរបស់គាត់)។

[28] **E1/178.1** ប្រតិចារឹក, ៩ មេសា ២០១៣, Francois Ponchaud, ទំព័រ៦-៧ [09.25.47-09.28.07]។

[29] **E9/13.1** ឧបសម្ព័ន្ធ, ទំព័រ៦។

[30] **E1/178.1** ប្រតិចារឹក, ៩ មេសា ២០១៣, Francois Ponchaud, ទំព័រ៨៤ [15.11.46-15.14.54] ("យើងត្រូវតែប្រុងប្រយ័ត្ន ពីព្រោះយើងចង់ឲ្យបានការពិត ហើយជនភៀសខ្លួនអាចបំភ្លើសសាច់រឿងរបស់ពួកគេដើម្បីការពារខ្លួនឯង"), ៨៥ [15.14.54-15.17.08] ("ខ្ញុំមានប្រភពព័ត៌មានពីរ។ ព័ត៌មាននេះត្រូវបានប្រមូលតាមបែបវិទ្យាសាស្ត្រ។ ខ្ញុំដាក់បញ្ចូលគ្នាដើម្បីឲ្យខ្ញុំអាចទទួលបាននូវរូបភាពពេញលេញ ហើយប្រភពទាំងពីរបានបន្ថែមទម្ងន់ឲ្យគ្នាទៅវិញទៅមក")។

[31] **E9/13.1** ឧបសម្ព័ន្ធ, ទំព័រ៦។

14. Stephen Heder ក៏ជាមនុស្សម្នាក់ដែលមានជំនាញយ៉ាងទូលំទូលាយ អំពីបញ្ហាទាក់ទងនឹងសម័យកម្ពុជាប្រជាធិបតេយ្យ។ អស់រយៈពេលជាង៣០ឆ្នាំ លោក Heder បានដឹកនាំត្រួតពិនិត្យយ៉ាងទូលំទូលាយទៅលើឯកសារដែលពាក់ព័ន្ធនឹង បកក និងកម្ពុជាប្រជាធិបតេយ្យ ដោយសហការជាមួយអ្នកជំនាញកម្ពុជាផ្សេងទៀត និងបានសម្ភាសជាមួយកម្មាភិបាល បកក និងពលរដ្ឋកម្ពុជាជាច្រើននាក់ដែលធ្លាប់ទទួលផលប៉ះពាល់ពីរបបខ្មែរក្រហម រួមទាំង ខៀវ សំផន[32] អៀង សារី[33] និង វ៉ាន់ រិទ្ធិ[34]។ ការរកឃើញរបស់គាត់ត្រូវចងក្រងនៅក្នុងសៀវភៅជាច្រើន អត្ថបទសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងអត្ថបទបច្ចេកទេសបឋមស្តីពីខ្មែរក្រហម ប.ក.ក និងកម្ពុជាប្រជាធិបតេយ្យ រួមទាំង បេក្ខជនប្រាំពីរនាក់សម្រាប់ការចោទប្រកាន់ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានារបស់ពួកខ្មែរក្រហម (Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge),[35] កុម្មុយស្តនិយមកម្ពុជា និងគំរូរបស់វៀតណាម: ការយកគំរូតាម និងឯករាជ្យភាព ឆ្នាំ១៩៣០ ដល់១៩៧៥ (Cambodian Communism and the Vietnamese Model: Imitation and Independence, 1930-1975), និង ប៉ុល ពត និង ខៀវ សំផន (Pol Pot and Khieu Samphan[36])។ Heder ក៏ធ្លាប់បំរើការងារជាអ្នកវិភាគ និងអ្នកស៊ើបអង្កេតនៅការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") និងក៏បានចូលរួមបន្ថែមទៀត ក្នុងសមត្ថភាពជាអ្នកពិគ្រោះយោបល់[37]ផងដែរនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។

15. ផ្ទុយទៅវិញ ដូចដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង ហើយដែលបានទទួលស្គាល់ដោយមេធាវីដូច្នោះដែរ គឺ Lemkin មិនអាចត្រូវពិចារណាថាជាអ្នកជំនាញបែបដូច្នោះបានទេ[38]។

---

[32] **E3/203** បទសម្ភាសន៍របស់ ខៀវ សំផន ដោយ Stephen Heder, គ្មានចុះកាលបរិច្ឆេទ។

[33] **E3/543** បទសម្ភាសន៍របស់ អៀង សារី ដោយ Stephen Heder, ១៧ ធ្នូ ១៩៩៦។

[34] **E9/13.1** ឧបសម្ព័ន្ធ, ទំព័រ១៩។

[35] **E3/48** Stephen Heder និង Brian D. Tittemore, *បេក្ខជនចំនួនប្រាំពីរនាក់ដែលត្រូវចោទប្រកាន់: គណនេយ្យភាពចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម (Seven Candidates for Prosecution: Accountability for the Crimes of the Khmer Rouge)*, មីនា ២០០៤។

[36] **E9/13.1** ឧបសម្ព័ន្ធ, ទំព័រ១៨-១៩។

[37] *ដដែលដូចខាងលើ*។

[38] **E294/1** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកភស្តុតាងថ្មី, ឲ្យចាប់ផ្តើមការស៊ើបអង្កេត និងឲ្យកោះហៅលោក ROB LEMKIN, ២៤ កក្កដា ២០១៣ កថាខណ្ឌ១៥។

ចំណេះដឹងរបស់គាត់អំពីប្រវត្តិរបស់ខ្មែរក្រហម និងអំពីកម្ពុជាប្រជាធិបតេយ្យ គឺនៅមានកម្រិត។ Lemkin ខ្លួនគាត់ផ្ទាល់ ទទួលស្គាល់ថាគាត់បានធ្វើទស្សនកិច្ចដំបូងនៅកម្ពុជា នៅខែកញ្ញា ឆ្នាំ ២០០៦ និងបានចំណាយពេលសរុបប្រមាណជា២២សប្តាហ៍នៅក្នុងប្រទេសនេះ[39]។ លើសពីនេះ គាត់ថ្លែងថាគាត់ទើបតែបានចាប់អារម្មណ៍លើខ្មែរក្រហមនៅឆ្នាំ១៩៩៨ប៉ុណ្ណោះ ហើយថា គាត់ "ចាប់ផ្តើមធ្វើការងារ" គំរោងការខ្សែភាពយន្តពីទ្វីបអឺរ៉ុបនៅដើមទសវត្សរ៍ឆ្នាំ២០០០ ក៏ប៉ុន្តែវាមិនច្បាស់លាស់ទេថាការងារអ្វីបែបនោះមានជាប់បន្តមកទៀត[40]។ ខណៈដែលគាត់អះអាងថាគាត់ធ្លាប់បានធ្វើ "ការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រដោយត្រឹមត្រូវ" ដើម្បីផលិតភាពយន្ត *សត្រូវរបស់ប្រជាជន* គាត់មិនបានផ្តល់ព័តអ្វីដែលទាក់ទងនឹងវិសាលភាពនេះទេ[41]។ គាត់ក៏នៅតែរក្សាថាគាត់បានពិគ្រោះយោបល់ជាមួយ "មេដឹកនាំក្នុងវិស័យនោះ" មួយចំនួនផងដែរ និងបានជួបមនុស្សជាច្រើនដែលធ្លាប់បានធ្វើការនៅអង្គជំនុំជម្រះនេះ ក៏ប៉ុន្តែគាត់មិនបានផ្តល់មតិយោបល់ ឬសេចក្តីពិស្តារអំពីអត្តសញ្ញាណ ឬចំនួនមនុស្សដែលគាត់បានពិគ្រោះយោបល់ មុខតំណែងរបស់ពួកគាត់ ឬក៏ប្រធានបទនៃការពិគ្រោះយោបល់នោះទេ[42]។

16. ហេតុដូច្នេះ វាមិនទំនងទេដែលអះអាងថាវិធីសាស្ត្ររបស់ Lemkin ស្តីពីរបៀបដែលភស្តុតាងត្រូវបានប្រមូលនោះ គឺត្រូវបានពន្យល់យ៉ាងគ្រប់គ្រាន់នៅចំពោះមុខ អជតក និងអាចត្រូវពឹងផ្អែកលើបាននោះ[43]។ នួន ជា គឺត្រូវ ដែលថា Lemkin ត្រូវបានសួរអំពីវិធីសាស្ត្ររបស់គាត់ក្នុងការប្រមូលភស្តុតាង[44] ប៉ុន្តែកិច្ចនេះ សូម្បីតែប្រហាក់ប្រហែលគ្នាតែបន្តិចក៏គ្មានផង ទៅនឹងរបៀប និងកម្រិតដែលអ្នកនិពន្ធនានានៃប្រភពបន្ទាប់បន្សំ ត្រូវបានរំពឹងថានឹងឲ្យពន្យល់ពីវិធីសាស្ត្ររបស់ពួកគាត់នៅក្នុងអំឡុងពេលនៃដំណាក់កាលសវនាការលើសំណុំរឿង០០២/០១ ដើម្បីឲ្យអង្គជំនុំជម្រះ

---

[39] **F2/4/3/1** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី Robert T.F. Lemkin, ទំព័រ៤, ឆ.៧ -ឆ.៩។

[40] *ដដែលដូចខាងលើ*, ទំព័រ៤, ឆ.១០។

[41] *ដដែលដូចខាងលើ*, ទំព័រ៥, ឆ.១៣។

[42] *ដដែលដូចខាងលើ*, ស្តែងឲ្យឃើញថា យ៉ាងហោចណាល់មានបុគ្គលិកតុលាការម្នាក់បានទាក់ទងជាមួយមេធាវី នួន ជា (សូមមើលឯកសារ E1/221.1 ប្រតិចារឹក ថ្ងៃទី១០ ខែកក្កដា ទំព័រ៧-៨ [09.19.10-09.23.09] ដែលសារអេឡិចត្រូនិចរបស់ Lemkin បានពិភាក្សា និងបានអានដូចគ្នាក្នុងកំណត់ហេតុ។

[43] **F2/4/3/3/1** ចម្លើយតប, កថាខណ្ឌ៧។

[44] *ដដែលដូចខាងលើ*, កថាខណ្ឌ៨។

សាលាដំបូង អាចធ្វើការវាយតម្លៃប្រកបដោយទំនុកចិត្តលើតម្លៃភវនីយភាពនៃកិច្ចការរបស់ពួកគាត់[45]។

17. ទីបី ជំនាញដែលនៅមានកម្រិតរបស់ Lemkin និងការពន្យល់របស់គាត់អំពីវិធីសាស្ត្រដែលបានយកមកប្រើបង្ហាញពីទស្សនៈមិនត្រឹមត្រូវរបស់អ្នកសម្ភាសន៍។ ឧទាហរណ៍ Lemkin ថ្លែងថា [redacted][46]។ គាត់មិនបានពន្យល់ទេ អំពីថាតើហេតុអ្វីបានជាអ្នកស្រាវជ្រាវនានាដែលស្វែងរកការពិតជាសត្យានុម័ត បង្ហាញជាដំបូងដល់ពួកអ្នកដែលត្រូវបានសម្ភាសនូវព័ត៌មានដែលបានមកដោយសារអំពើទារុណកម្ម។ គាត់បាននិយាយបន្តទៀតថា អ្នកដែលត្រូវបានសម្ភាសម្នាក់ៗ

[45] *សូមអាន, ឧទា.* **E1/221.1** ប្រតិចារឹក, ១០ កក្កដា ២០១៣, Stephen Heder, ទំព័រ២៥ [10.05.58-10.07.29] ("ខ្ញុំសូមចាប់ផ្តើមសួរលោកឲ្យលម្អិតបន្តិចអំឡុងពេល២០០៥ ពេលដែលលោកដឹកនាំក្រុម SOAS តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាតើកិច្ចសម្ភាសន៍ត្រូវធ្វើឡើងដោយរបៀបណា? តើវាមានការណែនាំឲ្យការរៀបចំជាសំនួរកត់ត្រា ហើយតើចម្លើយហ្នឹងត្រូវបានទទួលដោយរបៀបណា? លោកអាចរៀបរាប់ចំណុចនេះបានទេ?"), ទំព័រ៣៣ [10.26.13-10.27.43] ("លោករៀបរាប់អំពីបែបបទដែលលោកត់ត្រា។ តើអ្នកផ្សេងទៀតនៅក្នុងក្រុមនោះ គឺប្រើប្រព័ន្ធសួរសំនួរនិងឆ្លើយ ហើយកត់ត្រាទុក? តើគេរៀបចំសំនួរ ឬក៏បានថតជាខ្សែអាត់សម្លេងដែរឬទេ?"), ទំព័រ៥០ [11.28.29-11.29.45] ("លោក ហេដឌ័រ ខ្ញុំសូមសួរអំពីប្រភពនៃឯកសារនេះម្តងទៀតសូមលោកជួយបញ្ជាក់"), ទំព័រ៥១-៥២ ("លោក ហេដឌ័រ ខ្ញុំសូមសួរលោកអំពីប្រភពទី១ ដែលសរសេរថា "ជយោ ប៉ុល ពត!" តើលោកជម្រាបបានទេ? ហើយលេខយោងជើងទំព័រនេះក៏អាចជួយទៅដល់លោកផងដែរ")។ **E1/224.1** ប្រតិចារឹក, ១៦ កក្កដា ២០១៣, Stephen Heder, ទំព័រ៣០ [10.06.53-10.08.20] ("...លោកសាក្សីតើលោកអាចពន្យល់បានដែរឬទេ តាមការស្រាវជ្រាវរបស់លោក ក៏ដូចជាការសរសេរអត្ថបទរបស់លោក គឺថាបានឯកសារច្បាប់ដើមទាំអងស់នេះដោយរបៀបណា?"), ទំព័រ៣៤ [10.15.42] ("តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ? តើលោកធ្វើយ៉ាងណាអាចសម្រេចបានថា ចម្លើយសារភាពដែលមានហត្ថលេខាហ្នឹង គឺជាឯកសារច្បាប់ដើមដែលមានយថាភាពត្រឹមត្រូវ? តើលោកធ្វើយ៉ាងណាអាចដឹង?")។ **E1/178.1** ប្រតិចារឹក, ៩ មេសា , François Ponchaud, ទំព័រ៨៤ [15.10.10-15.11.46] ("លោកបានបញ្ជាក់ថា លោកបានព្យាយាមទទួលព័ត៌មានពីប្រភពផ្សេងៗ ដែលគេបានប្រាប់បាន -- អ៎! ឧទាហរណ៍ដូចជាវិទ្យុជាដើម។តើលោកអាចបញ្ជាក់អំពីប្រភពព័ត៌មានទាំងអស់ហ្នឹងបានទេ? ហើយហេតុអ្វីបានជាប្រភពព័ត៌មានទាំងនេះសំខាន់? ")។ **E1/179.1** ប្រតិចារឹក, ១០ មេសា ២០១៣ , François Ponchaud, ទំព័រ១១៥ [15.54.30] ("... មុននឹងសួរជនភៀសខ្លួនទាំងអស់នេះ អ្នកខ្លះគេបានប្រាប់ឈ្មោះពួកគាត់ហ្នឹងមុន។ តើអ៊ីចឹងមែនទេ? លោកឪពុកបានទទួលការឲ្យឈ្មោះជាមុនហើយ ឬក៏ការកត់សម្គាល់មុនហើយ")។ **E1/180.1** ប្រតិចារឹក, ១១ មេសា ២០១៣, François Ponchaud, ទំព័រ៤៨ [11.02.55-11.06.11] ("តើលោកបានដឹងថា លោក ម៉ៃខល វីកឃើរី ដែលបានរិះគន់លោកទៅលើបញ្ហាផ្សេងៗដូចជាគោលនយោបាយកាប់សម្លាប់នៅក្នុងតំបន់ផ្សេងៗ ហើយក្នុងនោះផងដែរនៅក្នុងការជ្រើសរើសជនភៀសខ្លួនដើម្បីសម្ភាសដំណើររឿងដែលលោកបានប្រើប្រាស់នៅក្នុងសៀវភៅរបស់លោកដែរឬទេ?")។

[46] **F2/4/3/3.1** កំណត់ហេតុ, ទំព័រ៤ ក្រោមចំណងជើងថា [redacted]។

សុទ្ធតែ [redacted] ដោយពុំបានធ្វើការពន្យល់ទេថា តើនោះជាសំណួមពររបស់អ្នកណា ឬថាតើហេតុអ្វីបានជាសំណួមពរបែបដូច្នេះត្រូវបានគេសួរទៅកាន់ "សាក្សី"[47]។ ដោយសារតែមានកំហុសធ្ងន់ធ្ងរនៅក្នុងវិធីសាស្ត្រ វាមិនអាចធ្វើឱ្យច្បាស់លាស់បានទេនៅក្នុងកំណត់ហេតុរបស់ Lemkin ដែលការអះអាងអំពីការសមគំនិតទាំងនោះ មានប្រភពចេញមកពីចម្លើយសារភាពនានានៅស-២១ ដែលមិនអាចទទួលយកបាន។

18. ដូចដែលត្រូវបានបង្ហាញដោយហេតុការណ៍នេះ និងដូចដែលត្រូវបានធ្វើឱ្យពិស្តារយ៉ាងវែងនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើទីមួយ និងទីពីររបស់ នួន ជា ស្នើសុំភស្តុតាងបន្ថែម[48] ដូច្នោះដែរ ថេត សម្បត្តិ មានទំនាក់ទំនងជាបុគ្គលជិតស្និទ្ធជាមួយនឹង នួន ជា ដែលធ្វើឱ្យអន្តរាយដល់សមត្ថភាពរបស់គាត់ ក្នុងការបំពេញសកម្មភាពជាអ្នកកាសែតម្នាក់ដែលឯករាជ្យ និងអព្យាក្រឹត នៅពេលមានគំរោងដែលជាប្រធានបទនៃកំណត់ហេតុ៖ ការទទួលខុសត្រូវរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[49]។ ថេត សម្បត្តិ បានលើកឡើងថាបានចំណាយពេលវេលាជាង១,០០០ម៉ោង នៅក្នុងការសម្ភាស នួន ជា ក្នុងរយៈពេល៦ឆ្នាំ[50] ហើយពួកគាត់ធ្លាប់បានទទួលស្គាល់ថាបង្កើតបានជាចំណងយ៉ាងជិតស្និទ្ធ។ ដូចដែលបានពិពណ៌នានៅក្នុង *នៅពីក្រោយវាលពិឃាត* ដូច្នោះដែរសៀវភៅដែល ថេត សម្បត្តិ បាននិពន្ធរួមនោះ ថេត សម្បត្តិ បានថ្លែងថា "ខ្ញុំបាននិយាយជាមួយ នួន ជា ច្រើនជាងខ្ញុំបាននិយាយជាមួយបងប្អូនខ្ញុំទៅទៀត។ ពួកយើងជិតស្និទ្ធនឹងគ្នាណាស់។ ខ្ញុំបានជជែកជាមួយ នួន ជា ច្រើនជាងខ្ញុំជជែកជាមួយបងប្អូនខ្ញុំ។ យើងមានភាពស្និតស្នាលនឹងគ្នា"[51]។ លើសពីនេះ សៀវភៅនេះផ្ទាល់មានចែងអំពី

---

[47] មនុស្សម្នាក់ដែលនៅរស់អាចមានសម្រាប់ Lemkin ដែលទំនងជាដឹងថាមានចម្លើយសារភាពជាច្រើនទៀតដែលត្រូវបានទទួលមកពី វស់ ញឹម តាមពិតទៅគឺ នួន ជា ដែលជាអ្នកគ្រប់គ្រងមន្ទីរស-២១ នៅពេលមានការចាប់ខ្លួន វស់ ញឹម នៅខែមិថុនា ឆ្នាំ១៩៧៨។

[48] **F2/2** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និងទីពីររបស់មេធាវីការពារក្តី នួន ជាសុំឱ្យទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែម ទាក់ទងទៅនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទៅក្នុងសំណុំរឿង០០២/០១, ១៦ កញ្ញា ២០១៤ (ចម្លើយតបទៅនឹងសំណើទីមួយ និងទីពីរ), កថាខណ្ឌ ១០។

[49] *ដដែលដូចខាងលើ* ។

[50] **E3/4202** សៀវភៅនិពន្ធដោយ GINA Chon និងលោក ថេត សម្បត្តិ មានចំណងជើងថា *"នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរក្រហមម្នាក់និងជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនរបស់គាត់"*, ទំព័រ៤, ERN (En) 00757478។

[51] *ដដែលដូចខាងលើ* , ទំព័រ ១៥២, ERN (En) 00757555។

ខប្រកាសមិនទទួលស្គាល់ថា “វាមិនមែនជាសៀវភៅអានអំពីរបប ខ្មែរក្រហមទេ ហើយវាក៏មិនមែនជាសៀវភៅប្រវត្តិសាស្ត្រដោយផ្អែកលើអង្គហេតុតែមួយមុខប៉ុណ្ណោះទេ, ភាគច្រើនវាចេញមកពីទស្សនៈយោបល់របស់ នួន ជា”[52]។ វាទំនងជាថា ទំនាក់ទំនងនេះ ទោះចង់ ឬមិនចង់ វាបានប៉ះពាល់ដល់ ថេត សម្បត្តិ ហើយតាមរយៈនោះវាបានប៉ះពាល់ដល់ Lemkin នៅក្នុងដំណើរការនៃការធ្វើសេចក្តី សម្រេចអំពីថាតើជាមួយនរណាដែលត្រូវធ្វើសម្ភាស តើសំនួរឬសម្ភារៈឯកសារអ្វីខ្លះដែលត្រូវសួរ ទៅកាន់សាក្សីនានា ហើយថាតើសម្ភារៈឯកសារអ្វីខ្លះ ដែលត្រូវជ្រើសរើសសម្រាប់ខ្សែភាពយន្ត និងសៀវភៅរបស់ពួកគាត់។

19. លើសពីនេះ វាមានលក្ខណៈច្បាស់លាស់ចេញពីខ្សែភាពយន្តរបស់ Lemkin និងបទសម្ភាសន៍ជាមួយនឹងចៅក្រមទទួលសិទ្ធិដែល នួន ជា គឺជាប្រភពចម្បងរបស់គាត់នៅក្នុងការកំណត់ថាតើមានអ្វីខ្លះកើតឡើងនៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានបកប្រែភាសា(ហើយដែលភាគច្រើនទំនងជាត្រូវបានធ្វើសេចក្តីសង្ខេប) ដោយ ថេត សម្បត្តិ។ នួន ជា បានជ្រើសរើសមិនផ្តល់សក្ខីកម្ម និងដាក់ខ្លួនគាត់ផ្ទាល់ឲ្យស្ថិតក្រោមការសួរដេញដោលអំពីបញ្ហានោះទេ ដែលវាជាបេះដូងនៃកំណត់ហេតុទាំងនេះ។ អំណះអំណាងដ៏អស្ចារ្យរបស់មេធាវីការពារក្តីដែលថាគាត់មិនមានបន្ទុកក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មនានាដែលហូរចេញពីគោលនយោបាយរបស់មជ្ឈឹមស្តីពីពួកខ្មាំងសត្រូវ ពីព្រោះឧក្រិដ្ឋកម្មលើបញ្ហាទាំងនោះត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលផ្សេងៗទៀត ដែលជាផ្នែកនៃសង្គ្រាមសម្ងាត់មួយនៅក្នុង បកក។ ការចូលរួមចំណែក និងឥទ្ធិពលរបស់ នួន ជា នៅក្នុងដំណើរការនៃការបង្កើតខ្សែភាពយន្ត សៀវភៅ និងកំណត់ហេតុ បានផ្តល់ជាពិសេសដល់រូបគាត់នូវវិធីមួយក្នុងការផ្តល់សក្ខីកម្ម ដោយពុំចាំបាច់ធ្វើតេស្តពិសោធលើការអះអាងរបស់គាត់ទៅតាមវិធីដ៏មានអត្ថន័យ ដែលការសួរសាក្សីរបស់គូភាគីបដិបក្ខធ្លាប់ត្រូវបានអនុញ្ញាតឲ្យធ្វើនោះឡើយ។

20. ចំពោះហេតុផលទាំងអស់នេះ កំណត់ហេតុទាំងនេះមានតម្លៃភស្តុតាងតិចតួច ឬក៏គ្មានទាល់តែសោះ ហើយគេមិនត្រូវទទួលយកទេ។

### *គ. កំណត់ហេតុទាំងនេះមិនមែនជា “កត្តាកំណត់” នៅក្នុងសាលក្រមទេ*

---

[52] *ដដែលដូចខាងលើ* , ERN (En) 00757472។

21. កំណត់ហេតុទាំងនេះមិនត្រូវទទួលយកធ្វើជាភស្តុតាងទេ ពីព្រោះពួកវាមិនមែនជា "កត្តាកំណត់" ក្នុងការបានឈានដល់សាលក្រមនោះឡើយ។ ព័ត៌មាននៅក្នុងកំណត់ហេតុទាំងនេះដែលជាសក្ខានុពលស្ថិតនៅក្រោមវិសាលភាពពេលវេលានៃការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃនោះ គឺមិនបានផ្តល់នូវមូលដ្ឋានអ្វីមួយសម្រាប់ធ្វើសេចក្តីសន្និដ្ឋានថាការសម្លាប់នៅទួលពោធិ៍ជ្រៃនោះ គឺមិនធ្វើទៅតាមគោលនយោបាយរបស់មជ្ឈឹមបក្ស ឬក៏មិនបដិសេធនូវការរកឃើញអំពីសិទ្ធិអំណាចតាមឋានានុក្រមមានប្រសិទ្ធិភាពនៅពេលនោះឡើយ។ លើសពីនេះ កំណត់ហេតុទាំងនេះមានផ្ទុកទៅដោយព័ត៌មានមិនត្រឹមត្រូវដែល Lemkin ខកខានមិនបានទទួលស្គាល់ដោយមកពីគាត់មិនមានជំនាញ។ ការខកខានមិនបានធ្វើតេស្តពិសោធអំពីភាពគួរឱ្យជឿបានលើបញ្ហាជាក់ស្តែង នឹងនាំឱ្យមានសំណួរបន្ថែមទៀតអំពីភាពគួរឱ្យជឿបាននៃ"ភស្តុតាង"ដទៃទៀតដែលមាន នៅក្នុងកំណត់ហេតុទាំងនោះ។

22. ការខ្វះខាតជំនាញរបស់ Lemkin និងភាពមិនគួរឱ្យទុកចិត្តបាននៃការវិភាគដែលមាននៅក្នុងកំណត់ហេតុរបស់គាត់ គឺត្រូវបានបង្ហាញនៅក្នុងការអះអាងរបស់គាត់នៅខែកក្កដា ឆ្នាំ១៩៧៥ [redacted][53]។ Lemkin ទំនង ជាមិនដឹងថា គេបានអនុញ្ញាតឱ្យភូមិភាគនីមួយៗទុកកងកម្លាំងយោធានោះទេ ហើយថាភូមិភាគពាយ័ព្យត្រូវបានមជ្ឈឹមអនុញ្ញាតឱ្យទុកយោធាចំនួនពីរកងពលដែលមួយកងពលមានយោធា៥,០០០នាក់[54]។ ដូច្នេះ វាមិនមានហេតុផលអ្វីដែលឱ្យ [redacted]

---

[53] **F2/4/3/3.1** កំណត់ហេតុ, ទំព័រ២ ក្រោមចំណងជើងថា [redacted]។

[54] *សូមអាន, ឧទា.* **E3/1170** មជ្ឈមណ្ឌលឯកសារកម្ពុជា បញ្ជីខ្មៅខ្មែរក្រហម, ERN (En) 00602544; ERN (Kh) 00443016; ERN (Fr) 00544895 (សៀវភៅកត់ត្រានៅស-២១ មានអង្គការលេខបង្ហាញពីយោធាពីកងពលធំនៅភូមិភាគពាយ័ព្យ។ (វាច្បាស់ណាស់ចេញពីការបកប្រែដើមពីភាសាខ្មែរ និងបារាំង ដែលថាការយោងទៅ "កងទ័ពនៅភូមិភាគពាយ័ព្យ") នៅក្នុងការបកប្រែជាភាសាអង់គ្លេសគឺជាកំហុសវាយអក្សរពុម្ព និងត្រូវអានថា"កងយោធានៅភូមិភាគពាយ័ព្យ"))។ **E319.1.27** កំណត់ហេតុស្តាប់ចម្លើយសាក្សី SCW-5, ១០ កញ្ញា ២០១៣, ត្រង់ ឆ.៩២ និង ឆ.៩៧-១០២ (ដោយបានរៀបរាប់ពីរចនាសម្ព័ន្ធនៃកងកម្លាំងយោធាភូមិភាគ នៅនៅភូមិភាគពាយ័ព្យ)។ សៀវភៅរបស់ E. Becker៖ *នៅពេលដែលសង្គ្រាមរលត់ទៅ*, ១៩៨៦, ទំព័រ១៨០, ERN (En) 00237885 ("although [Phim] had to give up two of his three army divisions to the Center, he was allowed to create one replacement division")។ **E3/494** របាយការណ៍អ្នកជំនាញការ Craig C. Etcheson, ១៨ កក្កដា ២០០១៧, ទំព័រ២៨, ERN (En) 00142853 ("The Constitution of Democratic Kampuchea describes the

[redacted] នោះទេ ដោយសារមានការដឹងឮ និងការយល់ព្រមយ៉ាងពេញលេញ ពីមជ្ឈិម យោធាចំនួន១០,០០០នាក់ ទុកនៅពាយ៉ព្យ ហើយរាយការណ៍ទៅ ញឹម ជាលេខាភូមិភាគ។

23. ឧទាហរណ៍មួយផ្សេងទៀត អាចត្រូវបានមើលឃើញតាមរយៈភាពជឿជាក់របស់ Lemkin ដែល គាត់អាចផ្តល់ឲ្យ គឺហាក់ដូចជាឲ្យដឹងថា រស់ ញឹម បានបន្ថែមសាវាចរដោយខ្លួនឯង [redacted][55]។ ទោះបីជាមិនប្រាប់ឈ្មោះក៏ដោយ គេមិនពិបាកស្រមៃឃើញថានរណាជាប្រភពនៃ ការអះអាងដូច្នេះដែរ ដោយហេតុថា ការដាក់ រស់ ញឹម ឲ្យទទួលខុសត្រូវចំពោះការបញ្ជាក្នុង [redacted] នឹងលើកទោសឲ្យ នួន ជា ពីការទទួលខុសត្រូវនេះ។ ចំណេះដឹងមាន កម្រិតរបស់ Lemkin អំពីយុគសម័យនៃកម្ពុជាប្រជាធិបតេយ្យ ធ្វើឲ្យគាត់ងាយជឿយ៉ាងមាន ប្រសិទ្ធិភាពទៅលើភាពខុសគ្នាមួយដែលមិនមានអត្ថិភាពនៅពេលនោះ។ គាត់ខកខានមិនបាន បំពេញឲ្យបានពេញលេញចំពោះពួកដែលមាន [redacted][56] នោះឡើយ។ ការពិត វាគួរ តែជាការប្រឆាំងមួយដែលងាកចេញពីគោលនយោបាយរបស់ បកក [redacted]

---

Revolutionary Army as being divided into three echelons, 'regular, regional and guerilla.' The 'regular' army consisted of divisions loyal to the center, as well as divisions whose primary loyalties were vested with 'regional' or Zone leaders.")។ និង **E3/130** លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា, ទំព័រ៧, មាត្រា១, ERN (En) 00184028 (distinguishing between the "Regular Army of the Center" and the "Regular Army of the Zone")។ **E3/424** កំណត់ហេតុស្តាប់ចម្លើយសាក្សី មាស វឿន, ១៦ ធ្នូ ២០០៩, ឆ.៦-ឆ.៧ និង **E1/130.1** ប្រតិចារឹក, ៤ តុលា ២០១២, មាស វឿន, ទំព័រ 19-20, 09.56.33-10.01.05 (អនុបញ្ជាការកងពលលេខ១ បានរៀបរាប់ថាតើកងពលមួយដែលមានយោធាចំនួន ២.៧០០នាក់ បន្តស្ថិតនៅក្រោមភូមិភាគនិរតីតាមរបៀបណា ហើយក្រោយមកត្រូវបានផ្លាស់ឲ្យទៅភូមិភាគបស្ចឹម ពីឆ្នាំ១៩៧៥-១៩៧៨)។ **E3/745** ទស្សនាវដ្តីទង់បដិវត្ត, ខែមីនា ឆ្នាំ១៩៧៨, ERN (En) 00504069 (បទឧទ្ទេសនាមរបស់ ប៉ុល ពត ដែលបានយោងដល់ "កងកម្លាំងយោធានៅភូមិភាគបស្ចឹម")។

[55] **F2/4/3/3.1** កំណត់ហេតុ, ទំព័រ៣-៤។

[56] [redacted]

[redacted][61]។ តាមពិត នេះគឺជាប្រធានបទនៃការពិភាក្សា នៅក្នុងវគ្គនៃសវនាការនាពេលអនាគតនៃសំណុំរឿងលេខ០០២/០២ មិនមែនសំណុំរឿងលេខ០០២/០១ នេះទេ ប៉ុន្តែវាបង្ហាញពីវិធីដែល Lemkin បានធ្វើការសន្និដ្ឋានមិនត្រឹមត្រូវ ដោយសារតែគាត់មិនមានជំនាញគ្រប់គ្រាន់។

57 *ដូចជើងទំព័រខាងលើ* ទំព័រ៥។

58 *ដូចជើងទំព័រខាងលើ* ។

59 *ដូចជើងទំព័រខាងលើ* ទំព័រ២។

60 *ដូចជើងទំព័រខាងលើ* ទំព័រ៣,៥។

61 [redacted]

24. ការអះអាងនៅក្នុងកំណត់ហេតុទាំងនោះ ដែលពាក់ព័ន្ធទៅនឹងពេលវេលានៃព្រឹត្តិការណ៍ ខែមេសា ឆ្នាំ១៩៧៥ នៅទួលពោធិ៍ជ្រៃ គឺមានស្រទាប់នៃភាពមិនគួរឱ្យជឿបាន ដែលរួមមានកំហុសឆ្គងដែល Lemkin ខកខានមិនបានកំណត់សញ្ញាណ ដោយមកពីគាត់មិនមានជំនាញ។ ឧទាហរណ៍ កំណត់ហេតុទាំងនោះបានលើកឡើងចោទប្រកាន់ថា [redacted][62]។ គេមិនដឹងពីប្រភពនៃការអះអាងនេះទេ ហើយឈ្មោះរបស់ពួកអ្នកដែលប្រឆាំងមិនត្រូវបានគេបញ្ជាក់ឱ្យច្បាស់លាស់ដែរ។ លើសពីនេះ គឺមិនមានគណៈអចិន្ត្រៃយ៍ដែលមានសមាជិកប្រាំបីនាក់ទេ។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ពីប្រភពនានាមួយចំនួនដែលបំពេញបង្គ្រប់គ្នា រួមមាន ខៀវ សំផន ដែលថា គណៈអចិន្ត្រៃយ៍មានសមាជិកចំនួនប្រាំពីរនាក់៖ ប្រាំនាក់ពេញសិទ្ធិ និងពីរនាក់ ជាសមាជិកត្រៀម[63]។ ចម្លើយតបរបស់ នួន ជា បានប៉ុនប៉ងបន្លំធ្វើឱ្យដូចជាមានការខ្វះចន្លោះ ដោយបានធ្វើការអះអាងថា វស់ ញ៉ឹម ក៏សមាជិកម្នាក់នៃគណៈអចិន្ត្រៃយ៍នោះដែរ ក៏ប៉ុន្តែបានទទួលស្គាល់នៅក្នុងកំណត់សម្គាល់ជើងទំព័រមួយថា រឿងនេះគឺ "មិនច្បាស់ទាំងស្រុងទេ" និងផ្អែកលើការ ដកស្រង់ចេញពីកំណត់ហេតុប្រជុំមួយរបស់គណៈអចិន្ត្រៃយ៍ ដែលបានរាយការណ៍ថា "ញ៉ឹម" មាន វត្តមាននៅខែមេសា ឆ្នាំ១៩៧៧ គឺជិតពីរឆ្នាំពេញ ក្រោយពេលមានការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ[64]។

---

[62] **F2/4/3/3.1** កំណត់ហេតុ, ទំព័រ១ ក្រោមចំណងជើងថា [redacted]។

[63] E313 សាលក្រម កថាខណ្ឌ២០៣, ៧៤៥ *យោង* **E1/95.1** ប្រតិចារឹក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២, David Chandler, ទំព័រ១២០ [បាននិយាយថាសមាជិកគណៈអចិន្ត្រៃយ៍បានដកចេញមកពីគណៈមជ្ឈិម]។ **E3/27** កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ទំព័រ១១ ERN (អង់គ្លេស) 00156751 ["គណៈអចិន្ត្រៃយ៍មានសមាជិប្រាំពីរនាក់៖ ប៉ុល ពត, នួន ជា, វន វ៉េត, សោ ភឹម, តាម៉ុក, សុន សេន និង អៀង សារី]។ **E1/54.1** ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២, កាំង ហ្គេចអ៊ាវ, ទំព័រ៧៣ [បាននិយាយថាសមាជិកគណៈអចិន្ត្រៃយ៍មានប្រាំពីរនាក់៖ (១) ប៉ុល ពត (២) នួន ជា (៣) សោ ភឹម (៤) អ៊ុំង ជឿន ហៅ ម៉ុក (៥) អៀង សារី (៦) វន វ៉េត និង (៧) សុន សេន]។ **E3/1714** របាយការណ៍របស់ S. Heder និង M. Matsushita: បទសម្ភាសន៍ជាមួយជនភាសខ្លួនកម្ពុជា នៅតាមព្រំដែនកម្ពុជា-ថៃ ចុះខែកុម្ភៈ-មីនា ឆ្នាំ១៩៨០ ទំព័រ៥៨ [បាននិយាយថា ក្នុងខែសីហា ឆ្នាំ១៩៧៨ គណៈអចិន្ត្រៃយ៍នៅដដែល គឺប្រាំពីរនាក់៖ ប៉ុល ពត, នួន ជា, តាម៉ុក, អៀង សារី, វន វ៉េត, សុន សេន និង កឺ (អនុលេខាភូមិភាគពាយ័ព្យ ដែលត្រូវបានប្រកាសនៅក្នុងវគ្គសិក្សានយោបាយ)]។

[64] **F2/4/3/3/1** ចម្លើយតប, កថាខណ្ឌ ៣ និង កំណត់សម្គាល់ជើងទំព័រ៦។ កត់សម្គាល់ថាឯកសារដែល នួនជា បានយោងនោះ គឺជាការដកស្រង់ទំនងជាចេញពីសៀវភៅមួយក្បាល និងសូម្បីតែវាសមជាសម្រង់មួយស្របច្បាប់ជាក់ស្តែងចេញពីកំណត់ហេតុអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ យ៉ាងណាក៏ដោយ ក៏វាគ្រាន់តែបង្ហាញថា ញ៉ឹម បានចូលរួមប្រជុំតែប៉ុណ្ណោះ ប៉ុន្តែគាត់មិនមែនជាសមាជិកម្នាក់នោះទេ។ ជាទូទៅ រាល់ការប្រជុំរបស់គណៈអចិន្ត្រៃយ៍ត្រូវបានចូលរួមដោយបុគ្គលម្នាក់ណាដែលមិនមែនជាសមាជិក ជាធម្មតាដើម្បីរាយការណ៍ពីអ្វីដែលបានកើតឡើងនៅក្នុងផ្នែកនៃអង្គការរបស់ខ្លួន។

25. ស្រដៀងគ្នានេះដែរ ការលើកឡើងចោទប្រកាន់ដែលថា [redacted] ត្រូវបានប្រឆាំងនឹង ប៉ុល ពត និងក្រុមរបស់គាត់[65] មកពីប្រភពមួយដែលគេមិនស្គាល់ ដែលឈ្មោះរបស់ពួកដែលប្រឆាំងនឹង ប៉ុល ពត គឺមិនមានលក្ខណៈជាក់លាក់ច្បាស់លាស់ទេ រីឯព័ត៌មាននោះទៀតសោតក៏មិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត។ ដោយផ្អែកលើភស្តុតាងដែលបានលើកឡើងនៅក្នុងអំឡុងពេលសវនាការ ដែលរួមមានទាំងកំណត់ហេតុដែល កសចស បានស្តាប់ចម្លើយ ខៀវ សំផន (ដែលជាសមាជិកគណៈមជ្ឈិម) នោះផង សូម្បីតែនៅកំពូលខ្ពស់បំផុតក្នុងទស្សវត្សរ៍ ឆ្នាំ១៩៧០ ក៏ដោយ ក៏គណៈមជ្ឈិមមានចំនួនសមាជិកពី ២០នាក់ ទៅ ៣០នាក់ប៉ុណ្ណោះ[66] [redacted] ។ Lemkin មិនបានពន្យល់អំពីរបៀបដែលគាត់អាចធ្វើការអះអាង បានថា [redacted] ។ មានសមាជិកនៃគណៈអចិន្ត្រៃយ៍តែម្នាក់គត់ដែល Lemkin បានអះអាងថា បាននិយាយជាមួយនោះគឺ នួន ជា។ គាត់ប្រហែលជាបានយោងផងដែរ ទៅដល់ឈ្មោះទាំងឡាយដែលមាននៅក្នុងបញ្ជីឈ្មោះនៅស-២១ ដែលត្រូវបានសម្លាប់ ឬដែលបានសារភាពថាក្បត់ខណៈដែលកំពុងត្រូវបានធ្វើទារុណកម្ម និងសួរចម្លើយនៅស-២១។ នៅក្នុងករណីណាមួយក៏ដោយ ការដែលមិនបានដឹងពីមូលដ្ឋាននៃការអះអាង បានកាត់បន្ថយបន្ថែមទៀតនូវតម្លៃភរនីយភាពនៃកំណត់ហេតុទាំងនោះ។ ចុងបញ្ចប់ សូម្បីតែ, *សម្រាប់គោលបំណងវែកញែក arguendo*, ការលើកឡើងចោទប្រកាន់ទាំងពីរ [redacted] គឺមានលក្ខណៈពិតមែនយ៉ាងណាក៏ដោយ ក៏ការលើកឡើងចោទប្រកាន់បែបដូច្នេះ គឺស្ថិតនៅឆ្ងាយណាស់ពីសក្ខីកម្មដែលថាបុគ្គលទាំងនោះដែលបានប្រឆាំងនឹង ប៉ុល ពត មិនមានជាប់ពាក់ព័ន្ធអ្វីទៅនឹងគោលនយោបាយរបស់បក្ស មួយសប្តាហ៍ក្រោយពេល

---

[65] **F2/4/3/3.1** កំណត់ហេតុ, ទំព័រ១ ក្រោមចំណងជើងថា [redacted] ។

[66] **E313** សាលក្រមសាលាដំបូង, កថាខណ្ឌ ២០២, *លើកយោង* **E1/95.1** ប្រតិចារឹក, ២៤ កក្កដា ២០១២, David Chandler, ទំព័រ១៣៨ ["គណៈកម្មាធិការមជ្ឈិម ខ្ញុំគិតថា មានចំនួនប្រហែល ២០នាក់"]។ **E3/27** កំណត់ហេតុនៃការសួរចម្លើយ ខៀវ សំផន, ១៣ ធ្នូ ២០០៧, ទំព័រ១១ ERN (អង់គ្លេស) 00156751 ["គណៈកម្មាធិការមជ្ឈិម មានសមាជិកជាង ៣០នាក់"]។ **E3/1714** របាយការណ៍ដោយ S. Heder និង M. Matsushita: បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ, កុម្ភៈ-មីនា ១៩៨០, ទំព័រ៥៩, ERN (អង់គ្លេស) 00170750 ["គណៈកម្មាធិការមជ្ឈិម មានសមាជិកប្រហែល ៣០នាក់ រួមទាំងសមាជិកពេញសិទ្ធិ និងសមាជិកបម្រុង"]។ **E1/69.1** ប្រតិចារឹក, ២៦ មេសា ២០១២, សាឡុត បាន, ទំព័រ២ [បញ្ជាក់ថា គាត់យកតាមការប៉ាន់ស្មានដែលផ្តល់ជូន កសចស ដែលថា គណៈកម្មាធិការមជ្ឈិមមានសមាជិកប្រហែល ២០នាក់ (សូមមើលផងដែរទំព័រ១ បង្ហាញថា ការប៉ាន់ស្មាននេះទាក់ទងនឹងក្របខណ្ឌពេលវេលារវាង១៩៧៥-១៩៧៦)]។

ជ័យជំនះកាន់កាប់ទីក្រុងភ្នំពេញ នៅពេលដែលគេបានរកឃើញថាមានការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ[67]។

26. ទោះបីជាកំណត់ហេតុទាំងនោះលើកឡើងចោទប្រកាន់ថា [redacted][68] នោះយ៉ាងណាក៏ដោយ ក៏ការណ៍នេះមិនបង្កើតបានជាភស្តុតាងដែលថាពួកមេដឹកនាំភូមិភាគបូព៌ា បានធ្វើសកម្មភាពផ្ទុយពីសេចក្តីណែនាំរបស់ពួកមេដឹកនាំបក្សនោះទេ។ ដូចគ្នានេះដែរ គេអាចនិយាយបាន [redacted][69] - កំណត់ហេតុទាំងនោះមិនបានចង្អុលពីអាកប្បកិរិយាជាក់លាក់ណាមួយ ដែលបង្ហាញថាពួកមេដឹកនាំភូមិភាគពាយ័ព្យ និងបូព៌ា មិនធ្វើតាមសេចក្តីណែនាំរបស់បក្សនៅពេលវេលាពាក់ព័ន្ធនោះទេ។

27. រាល់ព័ត៌មានដទៃទៀតទាំងអស់ដែលមាននៅក្នុងកំណត់ហេតុទាំងនោះ មានភាពពាក់ព័ន្ធអំពីពេលវេលាតិចតួច ឬគ្មានសោះតែម្តង ទៅនឹងការសម្លាប់ពួកទាហាន និងពួកមន្ត្រីរដ្ឋការ លន់ នល់ នៅទួលពោធិ៍ជ្រៃ នៅខែមេសា ឆ្នាំ១៩៧៥ និងការជម្លៀសប្រជាជនដោយបង្ខំលើកទីមួយ និងទីពីរ។ ការពិចារណារបស់ នួន ជា អំពីភាពពាក់ព័ន្ធនៃកំណត់ហេតុទាំងនោះបង្ហាញពីការយល់ឃើញទូលំទូលាយ ដែលគាត់ជឿថាមានការពាក់ព័ន្ធនឹងការទទួលយកភស្តុតាងនៅក្នុងបណ្តឹងសាទុក្ខ។

28. ឧទាហរណ៍ នួន ជា លើកឡើងថាកំណត់ហេតុនោះគួរត្រូវបានទទួលយក ដោយសារតែកំណត់ហេតុទាំងនោះបញ្ជាក់ថា ផែនការក្បត់ដើម្បីផ្តួលរំលំរបបនោះ ត្រូវបានរៀបចំជាមុន "ចាប់តាំងពី" មានការប្រជុំសម្ងាត់ដែលត្រូវបានធ្វើឡើងក្នុងខែឧសភា ឆ្នាំ១៩៧៥មកម្ល៉េះ[70]។ កាលបរិច្ឆេទខែឧសភា ឆ្នាំ១៩៧៥ មិនត្រឹមតែជាកាលបរិច្ឆេទក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃប៉ុណ្ណោះទេ ប៉ុន្តែកំណត់ហេតុទាំងនោះថែមទាំងមិនច្បាស់លាស់ [redacted] ដោយគ្រាន់តែនិយាយថា ការប្រជុំនោះ [redacted]

[67] **E313** សាលក្រម, កថាខណ្ឌ ៦៨១, ៦៨៤។

[68] **F2/4/3/3.1** កំណត់ហេតុ, ទំព័រ១ ក្រោមចំណងជើងថា [redacted]។

[69] *ដដែលដូចខាងលើ*។

[70] **F2/4/3/3/1** ចម្លើយតប កថាខណ្ឌ៦។

[redacted][71]។ ផ្នែកលើរយៈពេលការប្រជុំ [redacted] អំពើក្បត់ដែលបានលើកឡើង ដែលបានកើតឡើងដោយសារតែលទ្ធផលនៃការប្រជុំនោះ បានចាប់ផ្តើមក្រោយព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ[72] និងមិនបានផ្តល់ភ័ស្តុតាងណាមួយបញ្ជាក់ថា រស់ ញឹម មិនបានអនុវត្តតាមបទបញ្ជារបស់មជ្ឈិមបក្សក្នុងខែមេសា ឆ្នាំ១៩៧៥ នោះទេ។ ហើយពួកគេក៏មិនធ្វើឱ្យការរកឃើញនៃរចនាសម្ព័ន្ធគ្រប់គ្រងអំណាចជាធរមាននៅពេលសម្លាប់នោះ គ្មានភស្តុតាងបញ្ជាក់ដែរ។

29. បន្ទុកនៃការបង្ហាញភ័ស្តុតាងថ្មីគួរត្រូវបានទទួលយកនៅបណ្តឹងសាទុក្ខ គឺជាការទទួលខុសត្រូវរបស់ភាគីដែលដាក់ពាក្យប្តឹង[73]។ នួន ជា បានខកខានមិនបានបង្ហាញថាតើកំណត់ហេតុទាំងនោះមានស្ថានទម្ងន់ និងសារៈសំខាន់ ដើម្បីជាកកត្តាកំណត់ក្នុងការឈានទៅរកសាលក្រម ឬអត់នោះទេ ឬក៏ដើម្បីបង្ហាញថាកំណត់ហេតុទាំងនោះបញ្ជាក់លើអង្គហេតុទាំងឡាយដែលរូបគាត់បានអះអាង ក៏មិនបញ្ជាក់បាននោះដែរ។

### *ឃ. កំណត់ហេតុផ្នែកលើចម្លើយសារភាព ស-២១ ចំពោះការពិតនៃបញ្ហាដែលបានលើកឡើង*

---

[71] **F2/4/3/3.1** កំណត់ហេតុ ទំព័រ២ ចំណងជើង [redacted]។

[72] *ដូចជើងទំព័រខាងលើ* ទំព័រ២។ [redacted]

[73] **F2/5** សេចក្តីសម្រេចលើសាក្សី អ.ជ.ត.ក កថាខណ្ឌ១៦។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvočka និងអ្នកផ្សេងទៀត*, IT-98-30/1-A, សេចក្តីសម្រេចលើញត្តិរបស់ម្ចាស់បណ្តឹងសាទុក្ខសុំឱ្យទទួលយកភស្តុតាងបន្ថែមអនុលោមតាមវិធាន ១១៥ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៤ ទំព័រ៣ (កត់សម្គាល់ថា "ម្ចាស់បណ្តឹងសាទុក្ខ Prcać មិនបានបង្ហាញថា [ភ័ស្តុតាង] អាចជាកត្តាកំណត់ក្នុងការឈានទៅរកសេចក្តីសម្រេចនៅពេលសវនាការ)"។

30. សំណើរបស់ នួន ជា សុំឲ្យទទួលយកកំណត់ហេតុទាំងនេះ គួរត្រូវបានបដិសេធចោលផងដែរ ដោយសារតែបង្កើតឲ្យមានការព្យាយាមដោយប្រយោល ក្នុងការពឹងផ្អែកលើចម្លើយសារភាព ស-២១ ចំពោះការពិតនៃបញ្ហាដែលបានលើកឡើង។ ដូចដែលបានរៀបរាប់ខាងលើ កំណត់ហេតុទាំងនោះ និយាយថា [redacted][74]។ វាមិនអាចធ្វើទៅបានទេ ក្នុងការកំណត់ថា តើសាក្សីទាំងនោះទទួលរងឥទ្ធិពលពីព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពនោះក្នុងកម្រិតណា និងថាតើខ្លឹមសារនៃកំណត់ហេតុទាំងនោះឆ្លុះបញ្ចាំងពីឥទ្ធិពលនោះក្នុងកម្រិតណាដែរ ឬក៏គ្រាន់តែជាការសមគំនិតដែលមិនអាចទទួលយកបានពីចម្លើយសារភាព ស-២១ ទាំងនោះ។

31. កំណត់ហេតុនោះក៏ដកស្រង់[redacted][75]។ ភាពឆាប់រហ័សក្នុងការប្រើប្រាស់ខ្លឹមសាររបស់ចម្លើយសារភាពសម្រាប់គោលបំណងគាំទ្រ បន្តប្រាស់ចាកទៅនឹងភាពអាចជឿទុកចិត្តបាន និងតម្លៃភរនីយភាពនៃស្នាដៃទាំងមូលរបស់ Lemkin និង ថេត សម្បត្តិ ក៏ដូចជាការអះអាងដែលថា ពួកគេបានប្រើ "វិធីសាស្ត្រប្រុងប្រយ័ត្ន និងហ្មត់ចត់ដើម្បីវាយតម្លៃភាពអាចជឿទុកចិត្តបានរបស់បុគ្គលទាំងឡាយដែលពួកគេបានសម្ភាស"[76]។

32. ដូចដែលបានគូសបញ្ជាក់ម្តងហើយម្តងទៀតដោយសហព្រះរាជអាជ្ញា "ច្បាប់ជាតិ និងច្បាប់អន្តរជាតិ រារាំងដោយច្បាស់លាស់ដល់ភាគីមិនឲ្យប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ដើម្បីបង្ហាញសក្ខីកម្មពីការពិតនៃរឿងរ៉ាវនានាដែលបាន 'ឆ្លើយសារភាព'"[77]។ បន្ថែមលើនេះទៀត៖

[74] **F2/4/3/3.1** កំណត់ហេតុ ទំព័រ៤ ក្រោមចំណើងជើង [redacted]។

[75] *ដូចជើងទំព័រខាងលើ* ទំព័រ២ ក្រោមចំណងជើង [redacted]។

[76] **F2/4/3/3/1** ចម្លើយតប កថាខណ្ឌ៧។

[77] **F26/7** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង បញ្ជីឯកសារសាក្សី សម្រាប់ SCW-3, SCW-4 និង SCW-5 ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ កថាខណ្ឌ៥។

[តាមរយៈអង្គហេតុទាំងឡាយនៃសំណុំរឿងនេះ ការហាមឃាត់នេះអាចអនុវត្តយ៉ាងច្បាស់លាស់ក្នុងការរារាំង នួន ជា ដែលភ័ស្តុតាងក្នុងសំណុំរឿងលេខ០០២/០២ នឹងបង្ហាញថាគាត់បានគ្រប់គ្រងនៅគុក ស-២១ ដែលជាកន្លែងអ្នកទោសត្រូវបានធ្វើទារុណកម្មជាប្រចាំ និងគួរឲ្យភ័យខ្លាច មិនឲ្យប្រើប្រាស់ចម្លើយសារភាពដើម្បីបង្ហាញថារឿងរ៉ាវដែល "បានសារភាព" ជាការពិតឡើយ។ ពីព្រោះការណ៍នេះអាចលើកពីគោលបំណងដែលថា អំពើទារុណកម្មជាការធ្វើឲ្យឈឺចាប់ ដើម្បីធ្វើយុត្តិកម្មឧក្រិដ្ឋកម្មទាំងឡាយរបស់របបនោះ][78]។

33. តាមវិធាន៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង និងមាត្រា១៥ នៃវិធានស្តីពីអនុញ្ញាប្រឆាំងទារុណកម្ម កំណត់ហេតុទាំងនោះមិនគួរត្រូវបានទទួលយកបានទេ ដោយសារតែពួកវាពឹងផ្អែកលើភ័ស្តុតាង "ចម្លើយសារភាព" តាមរយៈការធ្វើទារុណកម្មដើម្បីបញ្ជាក់ការពិតលើរឿងរ៉ាវដែលបានរៀបរាប់នៅក្នុងចម្លើយសារភាពនោះ។

### *ង. វិធានការបន្ទាប់ដោយអង្គជំនុំជម្រះស្តីពីការស៊ើបសួរបន្ថែមគឺមិនចាំបាច់នោះទេ*

34. នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះនេះធ្វើការស៊ើបសួរបន្ថែមទៀតតាមការស្នើសុំរបស់ខ្លួន។ គោលការណ៍មួយក្នុងចំណោមគោលការណ៍ជាមូលដ្ឋានរបស់ អ.វ.ត.ក គឺថាកិច្ចដំណើរការនីតិវិធីត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ[79]។ កិច្ចស៊ើបសួរតាមផ្លូវតុលាការ *តាមភាគីតែម្ខាង* ក្នុងដំណាក់កាលបណ្តឹងសាទុក្ខនោះ គឺមិនមែនជាគោលការណ៍ចំពោះមុខនោះទេ។ ខុសពីកិច្ចស៊ើបសួរតាមផ្លូវតុលាការដែលធ្វើឡើងមុនពេលចេញដីកាដំណោះស្រាយ ភាគីទាំងឡាយមិនមានឱកាសដើម្បីតទល់ទៅនឹងភ័ស្តុតាងនៅពេលសវនាការនោះទេ។

35. លើសពីនេះទៀត ការទទួលយកភ័ស្តុតាងបន្ថែម ឬការកោះហៅសាក្សីនានានៅពេលបណ្តឹងសាទុក្ខដែលបានស្នើឡើងដោយភាគីតែម្ខាងនោះ មិនមានភាពយុត្តិធម៌ជាចំបងនោះទេ។ ប្រសិនបើអង្គជំនុំជម្រះចង់អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីបើកឲ្យមានការស្វែងរកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងឡើងវិញ សម្រាប់ជាការពិនិត្យបន្ថែមទៀត *ជាថ្មី*នោះ ភាគីទាំងអស់គួរត្រូវបានអញ្ជើញឲ្យដាក់ភ័ស្តុតាងបន្ថែមទៀតទាក់ទងទៅនឹងបញ្ហានេះ។ វាគឺជាកាតព្វកិច្ចរបស់ អ.ជ.ត.ក ក្នុងការ

[78] *ដូចជើងទំព័រខាងលើ* ត្រង់កថាខណ្ឌ៦។

[79] វិធាន ២១ (ក) នៃវិធានផ្ទៃក្នុង។

ធានាឲ្យបានថារាល់ភាគីទាំងអស់ រួមទាំងសហព្រះរាជអាជ្ញាផង ទទួលបានឱកាសយុត្តិធម៌ដើម្បីបង្ហាញភ័ស្តុតាងរបស់ខ្លួន[80]។

36. សារណារបស់ នួន ជា មិនបានបង្ហាញទាល់តែសោះថាការស៊ើបសួរបន្ថែមទៀតដោយអង្គជំនុំជម្រះតុលាការកំពូល អាចនាំទៅរកភ័ស្តុតាងដែលអាចជាកត្តាកំណត់ក្នុងសាលក្រមក្នុងសំណុំរឿង

[80] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Tadic, IT-94-1 សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញាស្នើសុំវិធានការការពារសម្រាប់សាក្សី និងជនរងគ្រោះ (អង្គជំនុំជម្រះសាលាដំបូង) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៥ កថាខណ្ឌ៥៥ (*"សវនាការដោយយុត្តិធម៌មិនមែនត្រឹមតែការប្រព្រឹត្តដោយយុត្តិធម៌នោះទេចំពោះជនជាប់ចោទ ប៉ុន្តែថែមទាំងចំពោះព្រះរាជអាជ្ញា និងសាក្សីផងដែរ"*)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Alekovski, IT-95-14/1 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាស្តីពីភាពអាចទទួលយកបាននៃភ័ស្តុតាង (អង្គជំនុំជម្រះតុលាការកំពូល) ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ កថាខណ្ឌ២៥ (*"ត្រូវបានមើលឃើញក្នុងវិធីនេះ វាពិបាកក្នុងការមើលឃើញថាតើសវនាការមួយអាចត្រូវបានចាត់ទុកថាមានយុត្តិធម៌ដែរទេ ប្រសិនបើជនជាប់ចោទបានទទួលផលប្រយោជន៍ពីអយ្យការលើសពីការអនុវត្តតាមដ៏តឹងរឹងតាមការការពារជាមូលដ្ឋានទាំងនោះ"*)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Haradinaj និងអ្នកផ្សេងទៀត* IT-04-84-A សាលដីកាបណ្តឹងសាទុក្ខ ចុះថ្ងៃទី១៩ កក្កដា ឆ្នាំ២០១០ កថាខណ្ឌ៤៦ (*"សេចក្តីសម្រេចនេះជាថ្មីម្តងទៀតបានកំណត់អាទិភាពមិនសមរម្យលើការពិចារណាតាមកត្តាវិទ្យាចំពោះសិទ្ធិរបស់អយ្យការក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌"*)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karemera និងអ្នកផ្សេងទៀត* ICTR-98-44-PT សាលដីកាលើការបំបែកសំណុំរឿង André Rwamakuba និង វិសោធនកម្មលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ (អង្គបុរេជំនុំជម្រះ) ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ២៦ (*"អង្គជំនុំជម្រះរំឭកឡើងវិញថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវអនុវត្តទាំងចំពោះមេធាវីការពារក្តី និងចំពោះអយ្យការ"*)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Zigiranyirazo, ICTR-2001-73-T សេចក្តីសម្រេចលើញត្តិរួមរបស់រដ្ឋអាជ្ញា (អង្គជំនុំជម្រះសាលាដំបូង II) ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១៨ (*"ការការពារសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីមានន័យថា ការធានាឲ្យមានភាពយុត្តិធម៌ក្នុងការដោះស្រាយសំណុំរឿងចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ខណៈដែលអង្គជំនុំជម្រះត្រូវតែយកចិត្តទុកដាក់ក្នុងការធានាឲ្យបានថា ជនជាប់ចោទមិនត្រូវបានរំលោភសិទ្ធិ អយ្យការក៏មិនត្រូវបានរារាំងក្នុងការបង្ហាញអំពីរឿងក្តីរបស់ខ្លួនដែរ"*)។ *ស្ថានភាពក្នុងប្រទេសយូហ្គេនដា* ICC-02/04-112 សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញា សុំអនុញ្ញាតប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចលើពាក្យសុំចូលរួមរបស់ជនរងគ្រោះ a/0010/06, a/0064/06 ដល់ a/0070/06, a/0081/06 ដល់ a/0104/06 និង a/0111/06 ដល់ a/0127/06m (អង្គបុរេជំនុំជម្រះ) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ២៧ (*"គេយល់ជាទូទៅថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ជាចំបងធានាដល់អត្ថប្រយោជន៍របស់ជនជាប់ចោទ ឬមេធាវីការពារក្តី។ ប៉ុន្តែ ភាពយុត្តិធម៌ក៏មានវិសាលភាពដល់ភាគីផ្សេងទៀតនៅក្នុងកិច្ចដំណើរការនីតិវិធី ដូចជាអយ្យការ"*)។ *ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ* ICC-01/04-135-tEN សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាសុំប្តឹងឧទ្ធរណ៍សេចក្តីសម្រេចរបស់អង្គជំនុំជម្រះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ លើពាក្យសុំចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរបស់ VPRS 1, VPRS 2, VPRS 3, VPRS 4, VPRS 5 និង VPRS 6 (អង្គបុរេជំនុំជម្រះ) ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ៣៨ (*"ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីរួមមាន ការគោរពដល់សិទ្ធិជានីតិវិធីរបស់រដ្ឋអាជ្ញា មេធាវីការពារក្តី និង ជនរងគ្រោះ"*)។

លេខ០០២/០១ នោះទេ។ ហេតុជំរុញដំបូងសម្រាប់ អ.ជ.ត.ក ក្នុងការទាក់ទង Lemkin និង ថេត សម្បត្តិ នោះគឺដើម្បីទទួលបានឈុតវីដេអូ។ នេះជាការឆ្លើយតបទៅនឹងការលើកឡើងនៅក្នុងបណ្ដឹងសាទុក្ខរបស់ នួន ជា ដែលថា Lemkin បានផ្ញើអ៊ីមែលមួយមកកាន់មេធាវីការពារក្ដី ដែលក្នុងអ៊ីមែលនោះបានបញ្ជាក់ថា រូបគាត់មានភស្តុតាង "សំខាន់" និង "ដោះបន្ទុក" ដែលនឹងបង្ហាញថាការផ្ដន្ទាទោស នួន ជា ចំពោះករណីទួលពោធិ៍ជ្រៃ គឺពិតជា "ខុសទាំងស្រុង"[81]។

37. ទោះជាយ៉ាងណា ការស្ដាប់ចម្លើយ Lemkin ដោយចៅក្រមទទួលសិទ្ធិ និង "កំណត់ហេតុ" ដែលគាត់បានផ្ដល់ឲ្យ បញ្ជាក់ច្បាស់ថាបទសម្ភាសន៍របស់សាក្សីទាំងបួននាក់ដែលគាត់បានធ្វើ មិនបានរៀបរាប់ដោយផ្ទាល់អំពីទួលពោធិ៍ជ្រៃនោះទេ វាមិនទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ ហើយឈុតវីដេអូដែលគាត់មាននោះ នឹងមិនត្រូវបានប្រគល់ជូននោះទេ។ កិច្ចស៊ើបសួរបន្ថែមអាចគ្រាន់តែពន្យារពេលកិច្ចដំណើរការនីតិវិធីវែងស្រាប់នៅក្នុងសំណុំរឿងនេះតែប៉ុណ្ណោះ ដោយមិនមានការរំពឹងទុកសមហេតុផលណាមួយថា អាចរួមចំណែកសំខាន់ដល់ការស្វែងរកការពិតនោះឡើយ ឬក៏ថាជាភស្តុតាងដែលអាចជាកត្តាកំណត់នៅក្នុងសាលក្រមសំណុំរឿងលេខ០០២/០១នោះដែរ ជាពិសេស ដោយពិចារណាទៅលើការបដិសេធរបស់ Lemkin និង ថេត សម្បត្តិ ក្នុងការមិនផ្ដល់ជូននូវឈុតវីដេអូដែលបានស្នើសុំនោះ។

38. វាច្បាស់ដែលថា ថេត សម្បត្តិ មានភស្តុតាងដែលពាក់ព័ន្ធខ្លាំង និងភស្តុតាងចោទប្រកាន់ខ្លាំងនៃបញ្ហាក្នុងវិវាទក្នុងសំណុំរឿងលេខ០០២/០២ គឺជាភស្តុតាងដែលបានមកផ្ទាល់ពីសម្ដីរបស់ នួន ជា។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាបានជម្រុញពីមុនមកហើយឲ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅ ថេត សម្បត្តិ ជាសាក្សីអាទិភាពក្នុងសំណុំរឿងលេខ០០២/០២ ប៉ុន្តែគាត់បានបដិសេធមិនព្រមសហការ[82]។ សហព្រះរាជអាជ្ញាធានាដល់ ថេត សម្បត្តិ ថាកិច្ចខិតខំប្រឹងប្រែងគ្រប់យ៉ាងនឹង

---

[81] F16 បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿងលេខ០០២/០១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ៨៣។

[82] ការមិនស្ម័គ្រចិត្តរបស់ ថេត សម្បត្តិ ក្នុងការសហការជាមួយតុលាការនេះ ក៏អាចត្រូវបានគេឃើញនៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា ស្នើឲ្យកោះហៅគាត់ជាសាក្សីអាទិភាពក្នុងសំណុំរឿងលេខ០០២/០២ ផងដែរ។ សហព្រះរាជអាជ្ញាចាត់ទុកភស្តុតាងរបស់គាត់ពាក់ព័ន្ធខ្លាំងទៅនឹងបញ្ហាដែលកំពុងជំនុំជម្រះក្នុងសំណុំរឿងលេខ ០០២/០២ នេះ ជាពិសេសនោះទាក់ទងទៅនឹងការបោសសំអាតផ្ទៃក្នុងរបស់កម្មាភិបាល ប.ក.ក ការប្រព្រឹត្តលើអតីតមន្ត្រីរដ្ឋការ និងទាហានរបប លន់ នល់ និងតួរនាទីរបស់ជនជាប់ចោទ។ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានទទួលសំណើរបស់សហព្រះរាជអាជ្ញា និងបានណែនាំឲ្យ WESU ទាក់ទងជាមួយ ថេត សម្បត្តិ និងធ្វើរបាយការណ៍មកអង្គជំនុំជម្រះត្រឹមថ្ងៃទី ២១

ត្រូវធ្វើ ដើម្បីឆ្លើយតបទៅនឹងកង្វល់អំពីសន្តិសុខផ្លូវច្បាប់របស់គាត់ និងសន្តិសុខរបស់ប្រភពព័ត៌មានរបស់គាត់ ហើយសង្ឃឹមថាគាត់នឹងពិចារណាឡើងវិញអំពីការបដិសេធមិនព្រមចូលរួមចំណែកក្នុងការលាតត្រដាងការពិតអំពីរបប ប៉ុល ពត តាមរយៈការផ្តល់សក្ខីកម្មនៅ អ.វ.ត.ក។ ទោះជាយ៉ាងណា រាល់ហេតុផលទាំងអស់ដែលបានពិភាក្សាខាងលើ មិនមានហេតុផលណាមួយដែលជឿថា ថេត សម្បត្តិ មានភ័ស្តុតាងដែលអាចជាកត្តាកំណត់នៅក្នុងសាលក្រមក្នុងសំណុំរឿងលេខ០០២/០១ នោះទេ ហើយការព្យាមបន្តទៀតដើម្បីស្វែងរកការស្តាប់សក្ខីកម្មរបស់គាត់នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខគឺមិនចាំបាច់នោឡើយ។

39. ដូចបានពិភាក្សាខាងលើ Robert Lemkin មិនមែនជាអ្នកជំនាញក្នុងរឿងខ្មែរក្រហមនោះទេ ហើយព័ត៌មានដែលគាត់បានដឹងអំពីសម័យនោះ ភាគច្រើនបានមកពីការបកប្រែផ្ទាល់មាត់ ឬការសង្ខេបនានាដែលផ្តល់ឲ្យតាមរយៈ ថេត សម្បត្តិ។ ដូច្នេះ មានហេតុផលកាន់តែតិចទៅទៀត ក្នុងការជឿជាក់ថា Lemkin អាចផ្តល់ភ័ស្តុតាងដែលអាចជាកត្តាកំណត់ ក្នុងសាលក្រមសំណុំរឿងលេខ០០២/០១ នោះ។

40. សម្អាងហេតុទាំងអស់នេះ ការពន្យារពេលកិច្ចដំណើរការនីតិវិធីដើម្បីស្តាប់ចម្លើយ ថេត សម្បត្តិ ការស្តាប់ចម្លើយ Lemkin ឡើងវិញ ឬកោះហៅពួកគេណាម្នាក់មកផ្តល់សក្ខីកម្មនោះ គឺមិនចាំបាច់

---

ខែឧសភា ឆ្នាំ២០១៥ អំពីលទ្ធភាពមានវត្តមានរបស់គាត់ដើម្បីផ្តល់សក្ខីកម្ម។ (*សូមមើល* E335/3 សេចក្តីសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅ ថេត សម្បត្តិ ជាសាក្សីអាទិភាព ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ទំព័រ៤)។

បន្ទាប់មក WESU បានផ្តួចផ្តើមឲ្យមានការឆ្លើយឆ្លងតាមអ៊ីមែល និងទូរស័ព្ទជាច្រើនជាមួយនឹង ថេត សម្បត្តិ។ នៅចុងបញ្ចប់នៃកិច្ចពិភាក្សាទាំងនេះ ថេត សម្បត្តិ បានប្រកាសថាគាត់មិនមានពេលមកផ្តល់សក្ខីកម្មនោះទេ ពីព្រោះថា (ក) "នឹងធ្វើឲ្យគាត់ គ្រួសាររបស់គាត់ និងចំនួនមនុស្សមិនជាក់លាក់ផ្សេងទៀតដែលគាត់បានធ្វើការជាមួយ ស្ថិតក្នុងកម្រិតហានិភ័យសន្តិសុខ ដែលយន្តការណ៍ការពាររបស់ អ.វ.ត.ក មិនអាចធានាសុវត្ថិភាពទៅមុខទៀតរបស់ពួកគេបាន មិនអាចធ្វើបានសូម្បីតែសម្រាប់មនុស្សទាំងអស់នោះដែលស្នាក់នៅក្នុងប្រទេសក្រៅពីកម្ពុជា" និង (ខ) "គាត់មិនអាចឆ្លើយសំណួរជាក់លាក់មួយចំនួនបានទេ ពីព្រោះគាត់ទទួលបានព័ត៌មានពីបុគ្គលផ្សេងទៀត ដែលមិនបានយល់ព្រមថា ព័ត៌មានរបស់ពួកគេត្រូវបានប្រើក្នុងទម្រង់ណាមួយផ្សេង ឬក្នុងគោលបំណងណាផ្សេង ក្រៅពីការផលិតខ្សែភាពយន្តរបស់គាត់"។ (*សូមមើល* **E335/3/2** របាយការណ៍បច្ចុប្បន្នភាពរបស់ WESU ឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង E335/3 ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥)។

នោះទេ[83]។ នួន ជា ខកខានមិនបានបង្ហាញឲ្យបានច្បាស់ថា ព័ត៌មានជាក់លាក់ដែលផ្តល់ឲ្យដោយ Lemkin ឬ ថេត សម្បត្តិ អាចជាកត្តាកំណត់នៅក្នុងសាលក្រម ឬជួយដល់ការស្វែងរកការពិត។

## IV. សេចក្តីសន្និដ្ឋាន

41. ចំពោះហេតុផលនានាដែលបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូល៖

១) បដិសេធសំណើសុំឲ្យទទួលយកកំណត់ហេតុទាំងនោះធ្វើជាភ័ស្តុតាង។

២) បដិសេធសំណើសុំកោះហៅ Robert Lemkin និង ថេត សម្បត្តិ ឲ្យផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ និង

៣) បដិសេធសំណើសុំឲ្យចៅក្រមទទួលសិទ្ធិធ្វើការស្តាប់ចម្លើយ Robert Lemkin និង ថេត សម្បត្តិ ឡើងវិញ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

[83] សូមមើល ការបញ្ជាក់ឡើងវិញរបស់ នួន ជា ចំពោះសំណើរបស់គាត់ ក្នុង F2/4/3/3/1 ចម្លើយតប កថាខណ្ឌ៩។